អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ២៨/២៤ ចេញផ្សាយ ខែមេសា ឆ្នាំ២០២៤

# សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុ

ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អ អាចជួយឱ្យស្ថាប័នសម្រេចគោលដៅរបស់ខ្លួន គឺតាមរយៈការរៀបចំផែនការថវិកា ការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយ ការគ្រប់គ្រងសាច់ប្រាក់ និងការវាយតម្លៃស្ថានភាពហិរញ្ញវត្ថុបានត្រឹមត្រូវជាដើម។

**និយមន័យ**



ការគ្រប់គ្រងហិរញ្ញវត្ថុអាចត្រូវបានកំណត់បានថា ការរៀបចំផែនការ ការរកប្រភព ការបែងចែក ការត្រួតពិនិត្យ ការប្រើប្រាស់ និងការរាយការណ៍ពីធនធានហិរញ្ញវត្ថុរបស់ស្ថាប័នដើម្បីសម្រេចឱ្យបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលជាអតិបរមានៃលទ្ធផលប្រតិបត្តិការ។ កត្តាចូលរួមក្នុងការសម្រេចក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាពមានដូចជាការរៀបចំផែនការថវិកា ការអនុវត្តថវិកា ការរៀបចំរបាយការណ៍គណនេយ្យស្តង់ដា ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្មផ្ទៃក្នុង និងខាងក្រៅជាដើម។

## ១.គោលបំណងនៃការគ្រប់គ្រងហិរញ្ញវត្ថុ

**ក. ប្រាក់ចំណេញអតិបរិមា÷** អ្នកគ្រប់គ្រងហិរញ្ញវត្ថុត្រូវតែកំណត់ឱកាសសម្រាប់កំណើនប្រកបដោយប្រសិទ្ធភាពខណៈពេលដែលកាត់បន្ថយហានិភ័យ។

**ខ. ការរក្សាស្ថិរភាព÷** អ្នកគ្រប់គ្រងហិរញ្ញវត្ថុត្រូវតែគ្រប់គ្រងលំហូរសាច់ប្រាក់ឱ្យបានល្អ និងធានាថាស្ថាប័នមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់គ្របដណ្តប់ចំណាយរយៈពេលខ្លីៗ។

**គ. ការគ្រប់គ្រងចំណាយ÷** ការគ្រប់គ្រងចំណាយបានត្រឹមត្រូវអាចធ្វើឱ្យប្រសើរឡើងនូវស្ថានភាពហិរញ្ញវត្ថុ និងស្ថិរភាពរបស់ស្ថាប័នទាំងមូល។

**ឃ. ការការពារផលប្រយោជន៍ម្ចាស់ភាគហ៊ុន÷** អ្នកគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវតែធ្វើការសម្រេចចិត្តដែលជាផលប្រយោជន៍ល្អបំផុតដល់ម្ចាស់ភាគហ៊ុនរួមបញ្ចូលទាំងការវាយតម្លៃហានិភ័យដែលទាក់ទងនឹងជម្រើសនៃការវិនិយោគផ្សេងៗដែលសមស្របបំផុតសម្រាប់ស្ថានភាព។

## ២. សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុ

ដើម្បីសម្រេចបាននូវគោលដៅហិរញ្ញវត្ថុ និងគោលបំណងរបស់ស្ថាប័ន អ្នកគ្រប់គ្រងហិរញ្ញវត្ថុត្រូវ ប្រើប្រាស់ព័ត៌មានដែលប្រមូលបានអំពីកំណត់ត្រាហិរញ្ញវត្ថុ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ ក្នុងការបែងចែកធនធានហិរញ្ញវត្ថុ។ សារៈសំខាន់នៃការគ្រប់គ្រងហិរញ្ញវត្ថុមានដូចខាងក្រោម÷


ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

**ក.** ការពង្រឹងជំនាញក្នុងការសម្រេចចិត្តគឺមានសារៈសំខាន់ណាស់សម្រាប់ការសម្រេចចិត្តក្នុងផ្នែកហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ។

**ខ.** ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អអាចជួយដល់ស្ថាប័នក្នុងការសន្សំសំចៃថវិកាលើឧបករណ៍ប្រើប្រាស់និងចំណាយផ្សេងៗទៀត។



**គ.** ពង្រឹងការវិនិយោគឱ្យមានភាពប្រសើរឡើងដែលអ្នកគ្រប់គ្រងហិរញ្ញវត្ថុប្រើប្រាស់យុទ្ធសាស្ត្រវិនិយោគ ជាច្រើនដើម្បីជួយឱ្យស្ថាប័នសម្រេចបាននូវគោលដៅហិរញ្ញវត្ថុរយៈពេលវែង។ ការវិនិយោគដែលបានគ្រោងទុកត្រឹមត្រូវនឹងអាចផ្តល់នូវស្ថិរភាព និងកំណើនក្នុងរយៈពេលវែងដល់ស្ថាប័ន។

**ឃ.** ការការពារពីវិបត្តិហិរញ្ញវត្ថុស្ថាប័នដែលគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនមិនបានល្អអាចនាំឱ្យមាន ផលវិបាកធ្ងន់ធ្ងរដូចជាការរឹបអូសទ្រព្យសម្បត្តិ ឬការក្ស័យធនជាដើម។

**ង.** ជាមាគ៌ាសម្រាប់ក្រុមប្រឹក្សាភិបាលដើម្បីបញ្ជាក់ឡើងវិញ ឬបង្កើតគោលនយោបាយហិរញ្ញវត្ថុឡើងវិញដោយផ្អែកលើគោលនយោបាយស្តង់ដាគណនេយ្យ។

**ច.** ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អក៏អាចវាស់វែងអំពីសមត្ថភាពរបស់ស្ថាប័នដើម្បីពង្រីកកម្មវិធីរបស់ស្ថាប័នផងដែរ។

**ឆ.** ផ្តល់ឱ្យស្ថាប័ននូវអត្ថប្រយោជន៍ដែលចាំបាច់លើការគ្រប់គ្រងធនធានដែលខ្វះខាត ពីព្រោះម្ចាស់ជំនួយយកចិត្តទុកដាក់ជាខ្លាំងទៅលើថវិកាជំនួយដែលប្រើប្រាស់ដោយស្ថាប័ន ហេតុនេះស្ថាប័នដែលមានជំហរហិរញ្ញវត្ថុល្អត្រូវបានចាត់ទុកថាមានប្រៀបលើស្ថាប័នដែលមានការគ្រប់គ្រងហិរញ្ញវត្ថុនៅមានកម្រិត។

**ជ.** បង្កើតនិងពង្រឹងភាពជឿជាក់របស់អ្នកពាក់ព័ន្ធមកលើស្ថាប័ន។

**ឈ.** ធានានូវការអនុវត្តគម្រោង ដូចដែលបានគ្រោងទុកដោយមានការបែងចែកថវិកា បានត្រឹមត្រូវគ្មានគម្រោងណាមួយត្រូវបោះបង់ដោយសារតែស្ថាប័នខ្វះមូលនិធិនៅចុងឆ្នាំនោះទេ។

**ញ.** បង្កើតឱ្យមានលំហូរសាច់ប្រាក់វិជ្ជមានក្នុងស្ថាប័ន។

**ដ.** ការពារទ្រព្យសម្បត្តិរបស់ស្ថាប័ន។

**ឋ.** ជួយស្ថាប័នក្នុងការរៀបចំផែនការដើម្បីបង្កើនមូលនិធិដោយខ្លួនឯងដែលធ្វើឱ្យមាននិរន្តរភាពក្នុងស្ថាប័ន។

**អត្ថបទ÷** លោក **ឡាំ ស៊ីនឿន**

**ឯកសារយោង÷១.** *ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ***



ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។